# សមាគមនិស្សិតខ្មែរនៅប្រទេសជប៉ុន

# ការប្រកួតប្រជែងអត្ថបទតែងសេចក្តី CSAJ ឆ្នាំ២០១០

*ប្រធានបទ*

*តើមានបញ្ហាសំខាន់ៗអ្វីខ្លះក្នុងប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជា?*

*តើយើងគួរធ្វើអ្វីខ្លះដើម្បីដោះស្រាយបញ្ហាទាំងនោះ?*


*ឈ្មោះបេក្ខជនៈ ងួន សុខសាន្ត (១៩ ឆ្នាំ)*

*និស្សិតផ្នែកសេដ្ឋកិច្ចឆ្នាំទី២ នៃសាកលវិទ្យាល័យកម្ពុជា*

*លេខទូរស័ព្ទ ០១១ ៧០៧ ៩០៤*

Email: soksan_ngoun@yahoo.com

*អាស័យដ្ឋានៈ ផ្ទះលេខ ៧៣៨ អឺអង ផ្លូវលេខ ១២៨ សង្កាត់ផ្សារដេប៉ូ២*

*ខណ្ឌទួលគោក ក្រុងភ្នំពេញ*

# សេចក្ដីសង្ខេប

ឆ្លងកាត់សង្គ្រាមជាច្រើនសតវត្ស ប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើស្ទើរតែគ្រប់វិស័យដែលក្នុងនោះ វិស័យអប់រំក៏ជាផ្នែកមួយដែលបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ រហូតមកទល់ពេលបច្ចុប្បន្ន គេសង្កេតឃើញថាវិស័យអប់រំទូទាំងប្រទេសពុំទាន់ឆ្លើយតបទៅតាមតំរូវការសង្គម និងនិន្នាការរីកចំរើនរបស់ពិភពលោកនៅឡើយ។ វិស័យនេះនៅតែប្រឈមមុខទៅនឹងបញ្ហាជាច្រើនដែលជាបុព្វហេតុ រាំងស្ទះដល់ការរីកចំរើនធនធានមនុស្ស ក៏ដូចជាមានទិ្ធពលអវិជ្ជមានទៅលើវឌ្ឍនភាពសង្គមកម្ពុជាទាំងមូល។ បញ្ហាចំបងៗក្នុងវិស័យអប់រំនៅកម្ពុជារួមមាន៖

- *វប្បធម៌ចំលងប្រ៊ុយយ៉ុងនិងការប្រើប្រាស់លុយសំណូកក្នុងការប្រលង* ដែលត្រូវបានគេសង្កេតឃើញជាទូទៅក្នុងទិដ្ឋភាពសង្គម
- *ប្រាក់បៀវត្សគ្រូបង្រៀនដែលមិនគ្រប់គ្រាន់សំរាប់ចំណាយ* ដែលធ្វើអោយគ្រូបង្រៀនពុំបានយកចិត្តទុកដាក់លើការបង្រៀន ប្រព្រឹត្តអំពើពុករលួយ ហើយពុំមានពេលវេលាក្នុងការស្រាវជ្រាវឯកសារបន្ថែមនានាដើម្បីពង្រឹងសមត្ថភាពខ្លួន
- *អត្រានៃចំនួននិស្សិតនៅមានកំរិតទាប* ដែលនេះបង្ហាញពីបរិមាណដ៏តិចតួចក្នុងការរួមចំណែកអភិវឌ្ឍន៍កសាងជាតិ
- *ជំនាញដែលសិក្សាពុំសូវឆ្លើយតបទៅនឹងតំរូវការសង្គម*

បញ្ហាប្រឈមទាំងនេះនឹងផ្តល់ផលអវិជ្ជមានទៅលើដំណើរការអភិវឌ្ឍន៍ជាតិកម្ពុជាដែលរួមមាន៖

- ភាពទន់ខ្សោយនៃការរៀបចំគោលនយោបាយជាតិនិងវិវឌ្ឍនភាពសង្គម
- បាត់បង់ឱកាសក្នុងការប្រកួតប្រជែង នៅពេលដែល ASEAN បង្កើតសហគមន៍សេដ្ឋកិច្ចខ្លួននៅឆ្នាំ ២០១៥
- កំណើនអត្រានិកម្មភាព ដោយសារទីផ្សារការងារតូចចង្អៀត

ដើម្បីដោះស្រាយក៏ដូចជាសំរាលនូវបញ្ហាប្រឈមដូចរៀបរាប់ខាងលើ គេគួរមានយន្តការមួយចំនួនដូចខាងក្រោម៖

- បង្កើនបរិមាណគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងការពង្រឹងគុណភាពអប់រំ
- ក្រសួងអប់រំយុវជននិងកីឡាគួរធ្វើការស៊ើរើ និងរៀបចំឡើងវិញនូវកម្មវិធីសិក្សាដែលមានលក្ខណៈទំនើបនិងបានធ្វើបច្ចុប្បន្ននីយកម្ម
- លុបបំបាត់រាល់អំពើពុករលួយ ការសូកប៉ាន់ ការលួចចំលងឯកសារនានា

- បង្កើតឡើងនូវកម្មវិធីប្រកួតប្រជែងផ្សេងៗដើម្បីពង្រឹងសមត្ថភាពនិង ភាពក្លាហាន របស់និស្សិត
- រៀបចំឱ្យមានវគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពសាស្ត្រាចារ្យក៏ដូចជាគ្រូបង្រៀននានា
- ធ្វើវិភាជន៍ចំណូលថវិកាជាតិអោយបាន សមស្របដើម្បីអោយគ្រូបង្រៀនទទួលបានបៀវត្សសមរម្យ
- សហការជាមួយម្ចាស់ជំនួយនិងវិស័យឯកជន ដើម្បីគៀងគរមូលនិធិជួយការអប់រំ
- គួរបង្កើតនូវហិបមូលនិធិមួយដែលតំរូវអោយក្រុមអភិជនកាត់ ចំណែកមួយចំនួននៃប្រាក់ចំណូលដ៏សន្ធឹកសន្ធាប់របស់ពួកគេ ដើម្បីជាមូលនិធិរួមចំណែកពង្រឹងវិស័យអប់រំ
- បង្កើតកម្មវិធីលើកទឹកចិត្តចំពោះនិស្សិតដែលសិក្សាជំនាញកសិកម្មនិងបច្ចេកទេស
- លើកទឹកចិត្តឱ្យមានកំណើនការវិនិយោគទៅលើវិស័យអប់រំ
- ប្រព័ន្ធផ្សព្វផ្សាយទាំងអស់គួរតែបង្កើតកម្មវិធីនានាដែលផ្តល់ចំណេះដឹងបន្ថែមដល់និស្សិតនិងប្រជាជនទូទៅ

## ១. សេចក្តីផ្តើម

**សង្គ្រាម** ជាពាក្យដែលប្រជាជនកម្ពុជានាពេលបច្ចុប្បន្នរួមទាំងរជនខ្មែរមួយចំនួនធំ តែងតែប្រើប្រាស់ដើម្បីរំលឹកដល់ភាពជូរចត់និងទុក្ខវេទនានៃប្រជាជនខ្មែរនាពេលអតីតកាល។ សង្គ្រាមរាំរ៉ៃជាបន្តបន្ទាប់បានអូសបន្លាយអស់រយៈពេលជាច្រើនសតវត្សនៅលើទឹកដីកម្ពុជាដែលគេធ្លាប់ចាត់ទុកជាប្រទេសដែលមានវប្បធម៌ អរិយធម៌ខ្ពង់ខ្ពស់ និងជាពិសេសជាទឹកដីសុវណ្ណភូមិដែលមានភាពសំបូរសប្បាយនិងជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខដុមនីយកម្ម។ ដោយឡែកប្រជាជនកម្ពុជារហូតដល់ជាង ២ លាននាក់ត្រូវបានសំលាប់និងស្លាប់នៅក្នុងសង្គ្រាមឈាមគ្នាឯងពោលគឺនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលដឹកនាំដោយលោក **សាឡុត ស** នេះឯង។ ទោះបីជារណសិរ្សសង្គ្រោះជាតិកម្ពុជានិងកងទ័ពវៀតណាមបានផ្តួលរំលំរបបដ៏ឃោរឃៅយ៉ាងនេះក្តី ក៏កម្ពុជាបានទទួលរងនូវភាពហិនហោចស្ទើរតែដល់ចំណុចសូន្យទៅហើយ។ កម្ពុជាត្រូវចាប់ផ្តើមស្តារឡើងវិញនិងធ្វើកំណែទំរង់ជាបន្តបន្ទាប់លើគ្រប់វិស័យ ដែលក្នុងនោះរួមមានវិស័យអប់រំក៏ជាទិសដៅអទិភាពយ៉ាងសំខាន់ផងដែរ។ ខណៈពេលដែលការអភិវឌ្ឍន៍របស់កម្ពុជាមានលក្ខណៈយឺតៗសន្សឹមៗ គេសង្កេតឃើញថាវិស័យអប់រំទូទាំងប្រទេសពុំទាន់ឆ្លើយតបទៅតាមតំរូវការសង្គម និងនិន្នាការរីកចំរើនរបស់ពិភពលោកនៅឡើយ។ តើអ្វីខ្លះដែលជាបញ្ហាចំបងនៅក្នុងវិស័យអប់រំកម្ពុជាដែលត្រូវតែដោះស្រាយជាបន្ទាន់? តើគេគួរមានយុទ្ធសាស្រ្តនិងយន្តការបែបណាដើម្បីកែលំអនូវស្ថានភាពនេះ?

## ២. បញ្ហាសំខាន់ៗក្នុងវិស័យអប់រំកម្ពុជា

ការអភិវឌ្ឍន៍របស់ប្រទេសមួយមានទំនាក់ទំនង យ៉ាងជិតស្និទ្ធិជាមួយនឹងអភិបាលកិច្ចល្អរបស់រដ្ឋាភិបាល ដោយដើរទន្ទឹមគ្នាជាមួយនឹងកិច្ចសហការល្អពីវិស័យឯកជន។ យ៉ាងណាមិញសមាសធាតុទាំងពីរនេះលេចឡើងបាន ក៏អាស្រ័យទៅនឹងធនធានមនុស្សនៅក្នុងប្រទេសនោះដែរដែលមានន័យជារួមថាការអភិវឌ្ឍន៍ពិតជាត្រូវការមូលធនបញ្ញាជាចាំបាច់។ ធនធានមនុស្សមិនមែនសំដៅទៅលើក្រុមមនុស្សដែលគ្រាន់តែបញ្ចប់ថ្នាក់មហាវិទ្យាល័យនោះឡើយតែគឺជាធនធានដែលមានចំណេះដឹងពិតប្រាកដនិងអាចចូលរួមចំនែកកសាងប្រទេសជាតិអោយរីកចំរើន។ យ៉ាងណាមិញ គេសង្កេតឃើញវិស័យធនធានមនុស្សនៅកម្ពុជាពុំទាន់មានភាពល្អប្រសើរនៅឡើយផ្ទុយទៅវិញ វាពោរពេញទៅដោយអំពើពុករលួយរវាងគ្រូនិងសិស្ស និងការចំលងឯកសារដោយបើកចំហ ។ លើសពីនេះ ភាពនៅមានកំរិតនៃចំនួននិស្សិតថ្នាក់មហាវិទ្យាល័យ និងការជ្រើសរើសមុខវិជ្ជាសិក្សារបស់និស្សិតកំរិតឧត្តមសិក្សាក៏នៅចោទជាបញ្ហានៅឡើយ។

### ២.១ វប្បធម៌ចំលងប្រ៊ុយយ៉ុងនិងការប្រើប្រាស់លុយសំណូកក្នុងការប្រលង

ការចំលងសំណៅឯកសារ រឺជាភាសាសាមញ្ញ *ប្រ៊ុយយ៉ុង* និងការប្រើប្រាស់ប្រាក់កាសក្នុងការសូកប៉ាន់ត្រូវបានសិស្សានុសិស្សនៅថ្នាក់វិទ្យាល័យរហូតដល់ និស្សិតសាកលវិទ្យាល័យចាត់ទុកថាជារឿងធម្មតានិងជាទំលាប់ស្រាប់ទៅហើយ ហើយពួកគេគិតថា ***នរណាទៅដែលទៅ***

*ប្រលងដោយដៃទទេ(គ្មានព្រីយ៉ុង)?* ដូចដែលមានពាក្យគេនិយមនិយាយថា ***បេក្ខជនប្រលងដែលគ្មានប្រ៊ុយយ៉ុងប្រៀបដូចទីក្រុងដែលគ្មានអគ្គិសនី*** ។ ទោះបីវាជាឃ្លាដែលសិស្សនិស្សិតនិយមយកប្រើប្រាស់ក្នុងន័យកំសាន្តសប្បាយក្តី ក៏វាបានឆ្លុះបញ្ចាំងពីទិដ្ឋភាពទូទៅក្នុងវិស័យអប់រំនៅកម្ពុជារួចទៅហើយ។ ចំពោះប្រ៊ុយយ៉ុងទាំងនេះ គេនឹងពុំអាចបើកមើលបានទេ ដរាបណាលោកគ្រូអ្នកគ្រូទទួលបន្ទុកការប្រលង(អនុរក្ស) ទទួលបានលុយសំណូកជាមុនសិន។ នាពេលថ្មីៗនេះ វិទ្យុអាស៊ីសេរីបានផ្សាយនូវអត្ថបទមួយដែលមានខ្លឹមសារថា ការសូកប៉ាន់គ្រូដែលជាអនុរក្សឬមេប្រយោគនៅក្នុង ពេលប្រឡងសញ្ញាបត្រទុតិយភូមិ នៅតាមមណ្ឌលប្រឡងមួយចំនួននៅប្រទេសកម្ពុជានៅតែបន្តកើតមានធ្ងន់ធ្ងរជាងឆ្នាំ ២០០៩ ក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះគឺថ្ងៃទី២៦និងថ្ងៃទី២៧ខែកក្កដា។[1] ហើយសិស្សជាច្រើនបាននិយាយថាការសូកប៉ាន់នេះអាស្រ័យទៅតាមមុខវិជ្ជាប្រលង ប្រសិនបើចំពោះមុខវិជ្ជាណាដែលស្រួលដូចជា ប្រវត្តិវិទ្យាគេត្រូវបង់៥០០០រៀលហើយមុខវិជ្ជាណាពិបាកដូចជា រូបវិទ្យា និង គណិតវិទ្យា គេត្រូវចំណាយ១៥០០០រៀល។[2] វប្បធម៌បើកចំលងនេះ ត្រូវបានបន្តអនុវត្តន៍មិនត្រឹមតែសិស្សវិទ្យាល័យប៉ុណ្ណោះទេ តែវាជាមូលដ្ឋានគំរូដែលពួកគេនឹងយកទៅប្រើប្រាស់នៅកំរិតឧត្តមសិក្សាថែមទៀត។

### ២.២. ប្រាក់បៀវត្សគ្រូបង្រៀនមិនគ្រប់គ្រាន់សំរាប់ចំណាយ

ទោះបីជាប៉ុន្មានឆ្នាំកន្លងមកនេះ គេសង្កេតឃើញមានការតំលើងប្រាក់បៀវត្សគ្រូបង្រៀនក៏ពិតមែន ក៏ប៉ុន្តែបរិមាណនេះពុំទាន់បានឆ្លើយតបទៅនឹង ជីវភាពរស់នៅបច្ចុប្បន្នរបស់ពួកគេឡើយ ពោលគឺមានសំទុះកំណើនទាបជាងអត្រាអតិផរណាក្នុងប្រទេស។ គេគួរកត់សំគាល់ថាទំនិញនៅលើទីផ្សារមានតំលៃកាន់តែខ្ពស់ទៅៗពីមួយថ្ងៃទៅមួយថ្ងៃ ខណៈពេលដែលប្រាក់ខែគ្រូបង្រៀនមានលក្ខណៈស្ទើរតែនៅទ្រឹង។ មនុស្សម្នាក់ៗតែងតែត្រូវបំពេញចាំបាច់នូវតំរូវការមូលដ្ឋានរបស់ខ្លួន ហេតុដូចនេះគ្រូបង្រៀនដែលទទួលបានបៀវត្សតិចប្រាកដជាស្វះស្វែងរកមធ្យោបាយដើម្បីបំពេញក្រពះខ្លួនជាពុំខានឡើយ។ បៀវត្សគ្រូបង្រៀនតិចជាបុព្វហេតុមួយបង្កអោយទិដ្ឋភាពវិស័យអប់រំកម្ពុជាមានសភាពអាក្រក់ជាពន់ពេក។ ដើម្បីទទួលបានប្រាក់បន្ថែម គ្រូភាគច្រើនត្រូវសំរេចចិត្តលក់ឯកសារផ្សេងៗក្នុងថ្នាក់រៀន បើទោះបីជាឯកសារខ្លះមានខ្លឹមសារដូចគ្នាទាំងស្រុងនឹងសៀវភៅពុម្ពរបស់ក្រសួងក៏ដោយ។ ម៉្យាងវិញទៀតដោយសារកន្លងមក ក៏មានសិស្សមួយចំនួនពុំបានទិញឯកសារទាំងនោះដែលជាមូលហេតុធ្វើអោយចំណូលក្រៅផ្លូវការរបស់ពួកគេធ្លាក់ចុះ ដូច្នេះលោកគ្រូអ្នកគ្រូបានកំរិតយកបរិមាណនៃឯកសារដែលបានទិញ ជាមូលដ្ឋានក្នុងការដាក់ពិន្ទុ។ បន្ថែមពីនេះការបង្រៀនលក្ខណៈឯកជន(គួរក្រៅម៉ោង) ត្រូវបានចាប់ផ្តើមជាបន្តបន្ទាប់។ គ្រូបង្រៀនពុំសូវយកចិត្តទុកដាក់ក្នុងការ

[1] វិទ្យុអាស៊ីសេរី *ការសូកប៉ាន់ក្នុងការប្រឡងសញ្ញាបត្រទុតិយភូមិនៅតែបន្តកើតមាន* ចុះផ្សាយថ្ងៃទី២៧ កក្កដា ២០១០
[2] Phnom Penh Post, *Exam monitors 'take money'*, issued on Wednesday, 28 July 2010 15:03

បង្រៀននៅម៉ោងរដ្ឋ (កំឡុងពេលបង្រៀននៅសាលារដ្ឋ) តែពួកគេនឹងយកចំណេះដឹងទាំងនោះទៅធ្វើអាជីវកម្មនៅម៉ោងគួរ។ ប្រការនេះធ្វើអោយសិស្សក្រីក្រដែលពុំមានលទ្ធភាពសិក្សាពុំអាចទទួលបានចំណេះដឹងពិតប្រាកដពី សាលារៀនដែលគេសិក្សាបានឡើយ។ លើសពីនេះទៅទៀត ដើម្បីរកចំណូលបន្ថែម លោកគ្រូអ្នកគ្រូមួយចំនួនបានទទួលសំណូកពីសិស្សក្នុងពេលប្រលង ដែលនេះឆ្លុះបញ្ចាំងពីអំពើពុករលួយក្នុងវិស័យអប់រំ។ ក្រៅពីការធ្វើអាជីវកម្មក្នុងការបង្រៀន លោកគ្រូអ្នកគ្រូភាគច្រើនបានបង្កើតមុខរបរផ្សេងទៀតដើម្បីបំពេញជីវភាពពួកគាត់ដែលវាជំរុញអោយគ្រូបង្រៀន ចំណាយពេលវេលាលើការប្រកបរបរផ្សេងៗទៀតជាជាងការស្រាវជ្រាវឯកសារផ្សេងៗក្នុងការពង្រឹងសមត្ថភាពខ្លួន។

### ២.៣ អត្រានៃចំនួននិស្សិតនៅតែមានកំរិតទាប

ដោយយោងទៅតាមការស្ទាបស្ទង់សុខភាពនិងប្រជាសាស្ត្រកម្ពុជាឆ្នាំ ២០០០ មានតែ ០.៨ ភាគរយនៃប្រជាជនសរុបប៉ុណ្ណោះដែលបានចូលសិក្សានៅថ្នាក់ក្រោយវិទ្យាល័យ។[3] ម៉្យាងទៀតទោះបីជាគេសង្កេតឃើញនៅឆ្នាំ ២០០៤-២០០៥ អត្រានៃការចុះឈ្មោះចូលរៀននៅថ្នាក់ឧត្តមសិក្សារបស់សិស្សានុសិស្សដែលបានបញ្ចប់ កំរិតវប្បធម៌មធ្យមសិក្សាទុតិយភូមិមាននិន្នាការកំនើនចំនួន ៩៩.៨ ភាគរយបើធៀបនឹងឆ្នាំសិក្សា ២០០៣-២០០៤[4] ក្តីក៏ចំនួននិស្សិតនៅមានបរិមាណតិចនៅឡើយ ពោលគឺមានចំនួនត្រឹមតែ ៥៣៥២៨ នាក់ប៉ុណ្ណោះដែលបានចុះឈ្មោះសិក្សានៅក្នុង ២៦ ស្ថាប័នរដ្ឋនិងឯកជន។ លើសពីនេះទៅទៀត របាយការណ៍ស្ទាបស្ទង់សង្គមសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ២០០៤ បានបង្ហាញថាត្រឹមតែ ១ ភាគរយប៉ុណ្ណោះក្នុងចំណោមប្រជាជនសរុបបានបញ្ចប់ការសិក្សាក្រោយថ្នាក់វិទ្យាល័យ។[5] និយាយជារួម ប្រទេសកម្ពុជាពុំទាន់មានធនធានគ្រប់គ្រាន់ សំរាប់ជុំរុញដំនើរការអភិវឌ្ឍន៍សង្គមនៅឡើយទេ រឺគេអាចនិយាយបានថាអត្រាដ៏តិចតួចនេះនឹងមិន អាចធ្វើអោយមានភាពរីកចំរើនបានឡើយ។ បន្ថែមពីនេះគេត្រូវយល់យ៉ាងច្បាស់ថា ក្នុងចំណោមនិស្សិតទាំងនោះគេពុំអាចសន្និដ្ឋានទេថានិស្សិតទាំងអស់សុទ្ធតែមានសមត្ថភាពពេញលេញ និងទទួលបានចំណេះដឹងពិតប្រាកដនោះឡើយ។ នេះក៏ពីព្រោះតែគុណភាពអប់រំនៅមានកំរិត ការស៊ីសំនូកសូកប៉ាន់នៅតែបន្តកើតមាននិងជាពិសេសការលួចចំលងសំណៅឯកសារនៅតែជាវប្បធម៌ក្នុងការសិក្សារបស់ ក្រុមសិស្សមួយចំនួនធំ។

### ២.៤ ជំនាញដែលសិក្សាពុំស្របឆ្លើយតបទៅនឹងតំរូវការសង្គម

#### ២.៤.១ តំរូវការជំនាញកសិកម្ម

នៅក្នុងឆ្នាំ ២០០៦ មាននិស្សិតចំនួន ៩៥៣១០ នាក់សិក្សានៅសាកលវិទ្យាល័យនៅក្នុងប្រទេសកម្ពុជា ដែលក្នុងចំណោមនិស្សិតទាំងនោះ ៩២ ភាគរយសិក្សាជំនាញ

[3] វិទ្យាស្ថានស្ថិតិជាតិ *សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៦* ទំព័រទី១២៨
[4] វិទ្យាស្ថានស្ថិតិជាតិ *សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៦* ទំព័រទី១២៨
[5] វិទ្យាស្ថានស្ថិតិជាតិ *សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៦* ទំព័រទី១២៨

ទាក់ទងនឹងសេវាកម្ម ៥ភាគរយទាក់ទងជំនាញអាជីវកម្ម និង ៣ភាគរយជំនាញកសិកម្ម ហើយយ៉ាងណាមិញមាននិស្សិតចំនួនតែ ១៦៩១២ នាក់ប៉ុណ្ណោះដែលបានសិក្សានៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។[6] កម្ពុជាតែងតែប្រកាសខ្លួនថាជាប្រទេសកសិកម្មដែលមានប្រជាជនជាង ៨០ ភាគរយជាកសិករ ប៉ុន្តែតើកម្ពុជាអាចជំរុញ ឱ្យមានកំនើនសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍ជាតិយ៉ាងពិតប្រាកដដែរបានរឺទេ ខណៈពេលដែលមានតែ ៣ ភាគរយប៉ុណ្ណោះនៃនិស្សិត សរុបទទួលបានការសិក្សាបច្ចេកទេសកសិកម្ម។

### ២.៤.២ គំរូវការជំនាញផលិតកម្ម

គេសង្កេតឃើញថាវិស័យកម្មន្តសាល(ផលិតកម្ម)ក្នុង ប្រទេសកម្ពុជាយើងពុំទាន់មានការរីកចំរើនល្អតលាស់ទេ ខណៈពេលដែលខ្លួនបានឈានជើងប្រឡូកក្នុងការប្រកួតប្រជែងថ្នាក់តំបន់និងពិភពលោកតាមរយៈការធ្វើសមាហរណ៍កម្មនានា។ កម្ពុជាបច្ចុប្បន្នពិតជាត្រូវការជាសារវន្តនូវការកែច្នៃផលិតផលកសិកម្មខ្លួនឱ្យក្លាយទៅជា ផលិតផលបែបឧស្សាហកម្ម ក្នុងគោលបំណងប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចជាមួយបណ្តាប្រទេសនានាលើពិភពលោក។ ផ្ទុយទៅវិញ កម្ពុជាស្ទើរតែគ្មានអ្នកដែលមានជំនាញផ្នែកផលិតកម្ម។ លើសពីនេះ គេពុំទាន់ឃើញមានសាកលវិទ្យាល័យ រឺសាលាបច្ចេកទេសណាដែលបើកបង្រៀន និងបណ្តុះបណ្តាលវិស័យនេះនៅឡើយទេ។ និស្សិតភាគច្រើនបានផ្តល់តំលៃលើ មុខជំនាញដែលមានលក្ខណៈអាជីវកម្មពោលដូចជាគណនេយ្យ គ្រប់គ្រង ម៉ាឃីតធីង (Marketing) ជាដើម ដោយពួកគេពុំបានដឹងថាតើគេអាចផលិតអ្វីដើម្បីដាក់លក់លើទីផ្សារនោះឡើយ។

# ៣ ផលអវិជ្ជមានដែលរាំងស្ទះដល់ការអភិវឌ្ឍន៍សង្គមជាតិ

## ៣.១. ភាពទន់ខ្សោយនៃការរៀបចំគោលនយោបាយជាតនិងវឌ្ឍនភាពសង្គម

ពាក្យចាស់បុរាណតែងតែលើកឡើងថា ទំពាំងស្នងឬស្សី រឺ យុវជនជាសសរទ្រូងនៃប្រទេសជាតិ ហេតុនេះហើយយុវជនជាពិសេសនិស្សិតនេះហើយនឹងប្រាកដក្លាយជាអ្នកដឹកនាំនាពេលអនាគតជាពុំខាន។ ចុះបើនិស្សិតទាំងនោះសុទ្ធតែមិនមែនជាធនធានមនុស្សពិតប្រាកដដែលអាចបំរើដល់ផលប្រយោជន៍ជាតិបាន តើសង្គមទាំងមូលនឹងទៅជាយ៉ាងណា? កាលណាពួកគេពុំមានចំណេះដឹងនិងភាពប៉ិនប្រសព្វគ្រប់គ្រាន់ទេ នោះការរៀបចំផែនការយុទ្ធសាស្រ្ត ដើម្បីអភិវឌ្ឍន៍ជាតិក៏មានកំរិតដែរ ពោលគឺកម្ពុជានឹងមិនអាចកាត់បន្ថយភាពក្រីក្រជាអតិបរមា មិនអាចធ្វើឱ្យសេដ្ឋកិច្ចខ្លួនរីកចំរើន និងអាចរហូតដល់កើតមានអស្ថេរភាពក្នុងសង្គម ទៀតផងដែលនេះនាំមកនូវកេរ្តិ៍ឈ្មោះស្អុយរលួយសំរាប់កម្ពុជា។ ម្យ៉ាងវិញទៀត សង្គមរីកល្អតលាស់ទៅបាន ក៏មិនអាស្រ័យតែទៅលើថ្នាក់ដឹកនាំដែរ។ ក្នុងករណីដែលប្រជាជនភាគច្រើនមិនទាន់ទទួលបានការអប់រំគ្រប់គ្រាន់ទេ នោះពួកគេនឹងជួបប្រទះគ្រោះកាចយ៉ាងធ្ងន់ធ្ងរ តួយ៉ាងប្រហែលជាពួកគេពុំមានចំ



[6] CAMFEBA, *យុវជននិងការងារ ការបំពេញគំលាតបំនិន ឆ្នាំ២០០៨* ទំព័រទី ១៥

ណោះដឹងគ្រប់គ្រាន់ក្នុងការប្រកបរបរចិញ្ចឹមជីវិត ជីវភាពទន់ខ្សោយ បង្កអំពើចោរកម្មផ្សេងៗដែលទាំងនេះនាំមកនូវតែភាពឈឺក្បាលដល់រដ្ឋាភិបាលនិងជាឧបសគ្គរាំងរឹវឌ្ឍនកិច្ចសង្គមជាតិ។

### ៣.២. បាត់បង់ឱកាសក្នុងការប្រកួតប្រជែង

២០១៥ ជាសករាជថ្មីដែលសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថា ASEAN គ្រោងនឹងបង្កើតសហាគមន៍សេដ្ឋកិច្ចរបស់ខ្លួន ដោយតាមរយៈការរំលាយខ្លួនជាសហាគមន៍នេះ វានឹងជំរុញអោយមានលំហូរដោយសេរីនៃទំនិញនិងកំលាំងពលកម្មនៅក្នុងតំបន់។ ក្នុងនាមខ្លួនជាសមាជិក ASEAN កម្ពុជាត្រូវដឹងខ្លួនជាស្រេចថានឹងត្រូវប្រឈមនឹងការប្រកួតប្រជែងយ៉ាងខ្លាំងក្លា។ ប្រទេសយើងនឹងបាត់បង់នូវឧកាសប្រកួតប្រជែងជាមួយប្រទេសក្នុងតំបន់ បើសិនជាវិស័យអប់រំទូទាំងប្រទេសនៅតែស្ថិតក្នុងសភាពអាក្រក់បែបនេះ។ ប្រជាជនកាន់តែច្រើននឹងបាត់បង់ការងារធ្វើដោយសារការដណ្តើមទីផ្សារការងារពីសំណាក់ប្រទេសជិតខាង ហើយកម្ពុជានឹងរស់នៅដោយពឹង ផ្អែកតែទៅលើជំនួយបរទេសមួយមុខគត់។ លើសពីនេះ ប្រទេសនេះនឹងក្លាយជាទីផ្សារផលិតផលរបស់គេទាំងស្រុងហើយមានពំនាក់អាស្រ័យចំបងលើការនាំចូល ដែលជាបុព្វហេតុមួយធ្វើឱ្យមានអតុល្យភាពជញ្ជីងពាណិជ្ជកម្ម និងឈានទៅដល់អត្រាអតិផរណាខ្ពស់និងអប្រក្រតីភាព នៃអត្រាប្តូរប្រាក់រៀល។ កាឡាហាលសង្គមនឹងផ្ទុះឡើងហើយគ្មាននរណាទទួលរងគ្រោះក្រៅពី ប្រជាជនកម្ពុជាខ្លួនឯងឡើយ។

### ៣.៣. កំណើនអត្រានិកម្មភាព

ដោយសារតែនិស្សិតភាគច្រើនលើសលុប កំពុងផ្តោតការសិក្សាទៅលើតែជំនាញដែលទាក់ទងនឹងសេវាកម្មដែលរួមមានជំនាញគណនេយ្យហិរញ្ញវត្ថុ គ្រប់គ្រងអាជីវកម្ម ម៉ាឃីតធីង គ្រប់គ្រងទូទៅ ជាដើម ទាំងនេះនឹងបណ្តាលអោយទីផ្សារការងាររឹតតែតូចចង្អៀត ហើយអត្រានិកម្មភាពយុវជនមានកំណើនកាន់តែខ្ពស់ទៅៗ។ ពួកគេនឹងមិនសូវផ្តោតការយកចិត្តទុកដាក់លើការសិក្សាដូចកាលពីមុនឡើយ ហើយម្នាក់ៗបែរជាប្រឹងប្រែងស្វះស្វែងរកបទពិសោធន៍ការងារទៅវិញ។ នៅក្នុងឆ្នាំ ២០០៤ ក្នុងរាជធានីភ្នំពេញ ៧២ ភាគរយក្នុងចំណោមអ្នកគ្មានការងារសរុបជាយុវជនហើយមូលហេតុចំបងមួយនៃបញ្ហានេះគឺភាពខុសគ្នារវាងតំរូវការនិងការផ្គត់ផ្គង់បំណិននៅលើទីផ្សារការងារ។[7] អត្រានិកម្មភាពខ្ពស់យ៉ាងនេះនឹងបង្កអោយជីវភាពរស់នៅប្រជាជនអន់ខ្សោយ កំណើនអត្រាភាពក្រីក្រ និងបន្តបង្ខំអោយអ្នកដែលគ្មានការងារទាំងនោះប្រព្រឹត្តអំពើល្មើសច្បាប់និងអាជីវកម្មមិនសមស្របកាន់តែច្រើន។

## ៤. យន្តការនិងយុទ្ធសាស្ត្រសំរាប់កែលំអវិស័យអប់រំកម្ពុជា

### ៤.១.បង្កើនបរិមាណគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងការពង្រឹងគុណភាពអប់រំ

រាជរដ្ឋាភិបាលកម្ពុជាគួរតែធ្វើការវិភាជន៍ចំណូលថវិកាជាតិទៅកាន់វិស័យអប់រំអោយមានកំរិតសមល្មមដើម្បីបង្កើតឱ្យមានគ្រឹះស្ថានឧត្តមសិក្សារដ្ឋកាន់តែច្រើនដោយរួមទាំងការផ្តល់ឱកាស

[7] CAMFEBA, *យុវជននិងការងារ ការបំពេញគំលាតបំនិន ឆ្នាំ២០០៨* ទំព័រទី ៣១

សិក្សាដល់យុវជននៅតាមតំបន់ជនបទ តាមរយៈកម្មវិធីអាហារូបករណ៍រដ្ឋផងដែរ។ ទន្ទឹមនឹងនេះ ក្រសួងអប់រំយុវជននិងកីឡាគួរធ្វើការស៊ើរើ និង រៀបចំឡើងវិញនូវ កម្មវិធីសិក្សាដែលមានលក្ខណៈទំនើបនិងបច្ចុប្បន្ននីយកម្ម។ លើសពីនេះទៅទៀត ក្រសួងគួរសហការនឹងស្ថាប័នពាក់ពន្ធ័រួមជាមួយនឹងគ្រឹះស្ថានសិក្សាទាំងអស់ ដើម្បីសំដៅធ្វើយ៉ាងណាលុបបំបាត់រាល់អំពើពុករលួយ ការសូកប៉ាន់ ការលួចចំលងឯកសារនានាក្នុងគោលបំណងធានាឱ្យបាននូវគុណភាពអប់រំខ្ពស់។ ម្យ៉ាងវិញទៀត គេគួរបង្កើតឡើងនូវកម្មវិធីប្រកួតប្រជែងផ្សេងៗដើម្បីពង្រឹងសមត្ថភាពនិងភាពក្លាហានរបស់និស្សិត។ បន្ថែមពីនេះ ក្រសួងអប់រំគួរតែរៀបចំឱ្យមានវគ្គបណ្ដុះបណ្ដាលបង្កើនសមត្ថភាពសាស្ត្រាចារ្យក៏ដូចជាគ្រូបង្រៀននានាផងដែរ។

## ៤.២. តំលើងប្រាក់បៀវត្សគ្រូបង្រៀន

ដោយសារបញ្ហាប្រាក់ខែគ្រូបង្រៀនជាមូលហេតុចំបង ដែលធ្វើអោយវិស័យអប់រំចុះខ្សោយ រាជរដ្ឋាភិបាលគួរលៃលកធ្វើយ៉ាងណាកាត់បន្ថយនូវការចំណាយខ្ជះខ្ជាយរបស់ខ្លួន និងបង្វែរទិសដៅទៅរកវិស័យអប់រំដែលជាវិស័យស្នូល។ គេគួរធ្វើវិភាជន៍ចំណូលថវិកាជាតិអោយបានសមស្រប ដើម្បីអោយគ្រូបង្រៀនទទួលបានបៀវត្សដ៏សមរម្យមួយ។ លើសពីនេះទៅទៀត រដ្ឋាភិបាលគួរធ្វើការសហការជាមួយម្ចាស់ជំនួយនិងវិស័យឯកជន ដើម្បីគៀងគរមូលនិធិមួយចំនួនក្នុងការជួយដោះស្រាយជីវភាពគ្រូបង្រៀន ក៏ដូចជាជួយជំរុញបង្កើនគុណភាពអប់រំនៅកម្ពុជា។ ក្រៅពីនេះទៅទៀត រដ្ឋគួរបង្កើតនូវហិបមូលនិធិមួយដែលតំរូវអោយក្រុមអភិជនកាត់ចំណែកមួយចំនួននៃប្រាក់ចំណូលដ៏សន្ធឹកសន្ធាប់របស់ពួកគេ ដើម្បីជាមូលនិធិរួមចំណែកពង្រឹងវិស័យអប់រំហើយមូលនិធិទាំងនោះគួរត្រូវបានរក្សាទុកដោយមានសុវត្ថិភាពក្នុងគណនីធានាគារមួយ ដែលនេះមិនត្រឹមតែជួយដល់គ្រូបង្រៀនទេ តែរដ្ឋក៏អាចទទួលបានការប្រាក់មួយចំនួនបន្ថែមសំរាប់ការវិនិយោគនេះ។

## ៤.៣. បង្កើតកម្មវធីលើកទឹកចិត្តចំពោះនិស្សិតដែលសិក្សាជំនាញសំខាន់ៗ

ក្រសួងគួរយកចិត្តទុកដាក់ទៅលើការបង្កើតកម្មវិធីលើកទឹកចិត្ត ទាំងផ្នែកសំភារៈនិងហិរញ្ញវត្ថុចំពោះនិស្សិតដែលសិក្សាជំនាញសំខាន់ៗដូចជា កសិកម្មនិងបច្ចេកទេសជាដើម។ ម្យ៉ាងទៀតដោយសារតែចំណេះដឹងផ្នែកបច្ចេកទេសរបស់កម្ពុជានៅមានកំរិត គេគួរមានកម្មវិធីបញ្ជូននិស្សិតទាំងនោះទៅសិក្សានៅក្រៅប្រទេស ដើម្បីពង្រឹងសមត្ថភាពព្រមទាំងចំណេះដឹង បច្ចេកទេសថ្មីៗទំនើបៗបន្ថែមទៀត។ ការធ្វើដូច្នេះនឹងជំរុញអោយបរិមាណធនធានមនុស្សផ្នែកកសិកម្មនិងបច្ចេកទេសមានកំណើនកើនខ្ពស់ ដែលវាជាតំរូវការចាំបាច់បំផុតសំរាប់កម្ពុជា។ ធនធានមនុស្សទាំងនេះនឹងជួយប្រជាជនខ្មែរមានការយល់ដឹងពីបច្ចេកទេសកសិកម្មនិង ចំនេះដឹងផ្សេងទៀតដែលធ្វើអោយប្រជាជនមានជីវភាពកាន់តែប្រសើរ ហើយរដ្ឋក៏ទទួលបានកំនើនសេដ្ឋកិច្ចខ្ពស់ផងដែរ។ មូលធនបញ្ញាផ្នែកផ្សេងៗទៀតនឹងកើនឡើងជាលំដាប់ ដរាបណាប្រជាពលរដ្ឋយើងមានលទ្ធភាពកាន់តែច្រើនក្នុងការបញ្ជូនសមាជិកគ្រួសារទៅកាន់គ្រឹះស្ថានអប់រំ។

### ៤.៤. លើកទឹកចិត្តឱ្យមានកំណើនការវិនិយោគទៅលើវិស័យអប់រំ

ដោយសារលទ្ធភាពរបស់រដ្ឋាភិបាលក្នុងការកែលំអវិស័យអប់រំពុំមានច្រើន ដូច្នេះវាជាការប្រសើរបំផុតក្នុងការអនុញ្ញាតឱ្យមានការវិនិយោគកាន់តែច្រើនលើវិស័យនេះ។ ដើម្បីទាក់ទាញការវិនិយោគលើវិស័យនេះ រដ្ឋាភិបាលគួរគិតគួរទៅលើការបង្កើតបរិយាកាសធុរកិច្ចប្រសើរបំផុតតាមរយៈការសំរួលលិខិតបទដ្ឋានផ្សេងៗ រួមជាមួយបរិយាកាសច្បាប់និងនយោបាយផងដែរ។ គំរោងវិនិយោគទាំងនេះនឹងនាំមកនូវការ ប្រកួតប្រជែងផ្នែកឯកជនដែលបង្កឱ្យនិស្សិតបានទទួលអត្ថប្រយោជន៍ជាច្រើន ជាពិសេសសមត្ថភាពផ្នែកបច្ចេកវិទ្យាទំនើបៗ និងការអនុវត្តន៍ជាក់ស្តែងលើទ្រឹស្តី។ ម្យ៉ាងវិញទៀត កាលណាវិស័យធនធានមនុស្សមានការរីកចំរើន វាក៏បង្កភាពងាយស្រួលដល់ការវិនិយោគនានា ពោលគឺវិនិយោគិនពុំបាច់ព្រួយបារម្ភកង្វះធនធានមនុស្សក្នុងការបំរើការងារ។ នេះនឹងផ្តល់ផលប្រយោជន៍ដល់វិស័យឯកជន ក៏ដូចជាសំរាប់រដ្ឋាភិបាលនិង សំរាប់ប្រជាជនទាំងមូលផងដែរ។

### ៤.៥. ប្រព័ន្ធផ្សព្វផ្សាយគួរបំផុសពីការអប់រំ

ក្រៅពីតួនាទីរដ្ឋាភិបាលក្នុងការកែលំអវិស័យអប់រំនៅកម្ពុជា វិស័យឯកជនជាពិសេសប្រព័ន្ធផ្សព្វផ្សាយមហាជនក៏ដើរមុខនាទីយ៉ាងសំខាន់ដែរក្នុងការធ្វើអោយគុណភាពអប់រំកាន់តែមានភាពប្រសើរឡើង។ ប្រព័ន្ធផ្សព្វផ្សាយទាំងអស់គួរតែបង្កើតកម្មវិធីនានាដែលផ្តល់ចំណេះដឹងបន្ថែមដល់និស្សិតនិងប្រជាជនទូទៅ ហើយម្យ៉ាងទៀតគេគួរតែបំផុសស្មារតីសិស្សានុសិស្សខ្មែរអោយខិតខំសិក្សាស្វែងយល់ពីទិដ្ឋភាពសង្គមបច្ចុប្បន្នទាំងនៅក្នុងស្រុកនិងក្រៅស្រុក។

## ៥. សេចក្តីសន្និដ្ឋាន

វិស័យអប់រំនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងទស្សនៈវិស័យអភិវឌ្ឍន៍ជាតិរយៈពេលវែង ហើយគេពុំអាចមើលរំលងនូវកិច្ចខិតខំប្រឹងប្រែងជំរុញបង្កើនគុណភាពនៃមូលធនបញ្ញាឡើយ។ យ៉ាងណាមិញ គុណវិបត្តិជាច្រើននឹងក្លាយជាបន្ទុកយ៉ាងធ្ងន់ធ្ងរដែលនឹងធ្លាក់សង្កត់មកលើប្រទេស ដែលពុំបានយកចិត្តទុកដាក់កែលំអលើគុណភាពអប់រំខ្លួន។ គេនឹងបាត់បង់តម្លៃសង្គមនិងសេដ្ឋកិច្ចដែលគេមិននឹកស្មានដល់។ ហេតុដូច្នេះ យើងត្រូវខិតខំពួតដៃគ្នាកសាងធនធានមនុស្សនៅក្នុងប្រទេសកម្ពុជាយើងអោយមានគុណភាពនិងសមត្ថភាពខ្ពស់ ដើម្បីបំរើជាផលប្រយោជន៍សំរាប់សង្គមជាតិទាំងមូល៕